# បដិមាព្រះសិវក្នុងភាពជាឥសីរកឃើញនៅកំពង់ចាមកៅ

*កំពង់ចាមកៅ ជាឈ្មោះបុរាណដ្ឋានមួយ ស្ថិតនៅភូមិកំពង់ចាម ឃុំវើនសៃ ស្រុកវើនសៃ ខេត្តរតនគិរី (ពីមុនមកជាដែនដីនៃខេត្តស្ទឹងត្រែង)។ បុរាណដ្ឋានកំពង់ចាមកៅ រកឃើញដោយលោក* Louis Klein *នៅក្នុងឆ្នាំ១៩១១ ដែលពេលនោះ លោកមានតួនាទីជាប្រធានប្រតិភូប្រចាំតំបន់មុលប៉ាមោក ក្នុងខេត្តស្ទឹងត្រែង។ លោក* Henri Parmentier *បានប្រែអត្ថន័យឈ្មោះ "កំពង់ចាមកៅ" ថា "ទីក្រុងចាស់របស់ពួកចាម"។ នៅទីនោះ លោកបានប្រទះឃើញបដិមាចំនួន ២ អង្គ គឺបដិមាព្រះសិវក្នុងភាពជាឥសី និងបដិមាព្រះវិស្ណុ ហើយលោកបានបញ្ជូនបដិមាទាំងពីរនេះទៅកាន់សារមន្ទីរជាតិកម្ពុជានាឆ្នាំ១៩១១។ អ្នកស្រាវជ្រាវមុនៗយល់ថា បដិមាព្រះសិវក្នុងភាពជាឥសីនេះ មានអាយុកាលស.វ.ទី៧ ហើយជាបដិមាព្រះសិវដែលមានលក្ខណៈកម្រនៅក្នុងសិល្បៈខ្មែរនាសម័យចេនឡា ព្រោះជាទូទៅគេតែងកសាងលិង្គតំណាងឱ្យព្រះសិវ ជំនួសឱ្យការកសាងរូបបដិមាព្រះសិវក្នុងទម្រង់ដូចមនុស្ស។ តើបដិមានេះមានលក្ខណៈដូចម្ដេចខ្លះ?*

*បដិមានេះកសាងឡើងអំពីថ្មភក់ មានកម្ពស់ ១៧១,៥ ស.ម. ទទឹង ៥០,៥ ស.ម. និងកម្រាស់ ៣១ ស.ម.។ បន្ទាប់អំពីការរកឃើញ និងបានបញ្ជូនមកកាន់សារមន្ទីរជាតិកម្ពុជានៅក្នុងឆ្នាំ១៩១១ លោក* Henri Parmentier *បានរៀបរាប់ដោយសង្ខេបអំពីបដិមានេះនៅក្នុងអត្ថបទស្រាវជ្រាវរបស់លោកនាឆ្នាំ១៩១៣ ដោយលោកបានហៅរូបបដិមានេះថា* ***"ព្រះសិវក្នុងភាពជាឥសី"*** *។ អ្នកស្រាវជ្រាវសម័យក្រោយមកទៀត មានជាអាទិ៍ លោក* George Groslier *១៩២៤ លោក* Pierre Dupont *១៩៣៦, ១៩៤១, លោក* John Guy *២០១៤ ក៏នៅតែបន្តហៅបែបនេះរហូតមកទល់ពេលបច្ចុប្បន្ន។ លោក* Pierre Dupont *យល់ថា បដិមានេះមានរូបរាង និងកម្ពស់ មិនសមាមាត្រជាមួយដងខ្លួនទាំងមូលឡើយ ព្រោះដងខ្លួនតូច គ្មានសាច់ដុំ និងជើងទាំងពីរវែងពេក។ បដិមានេះទៀតសោត មិនមានលម្អដោយគ្រឿងអលង្ការនៅលើព្រះកាយ មានពុកមាត់ និងបួងសក់វែងៗជាផ្នួងបែបឥសី ហើយមានព្រះនេត្រទីបីនៅលើថ្ងាស ដែលលក្ខណៈទាំងនេះហើយទើបគេអាចសន្និដ្ឋានថាជាព្រះសិវ (ឥសូរ) ក្នុងភាពជាឥសី។ ព្រះហស្តខាងស្ដាំបានបាក់អស់មួយកំណាត់ រីឯព្រះហស្តខាងឆ្វេងមានកាន់ថូទឹក (ឃ្មោក) ដែលអាចបញ្ជាក់អំពីឋានៈជា "យោគី" ឬ ជាអ្នកបួសដ៏ខ្ពង់ខ្ពស់។ ចំណុចនេះលោក* John Guy *យល់ថាជាលក្ខណៈសម្គាល់នៃរូបតំណាងព្រះសិវក្នុង*

*ទម្រង់ជាមនុស្ស ដែលចាប់ផ្ដើមមានឡើងដំបូងនៅដើមសម័យ គុប្ត នៃភាគខាងជើងប្រទេសឥណ្ឌា។ ប៉ុន្តែ ចំណុចដែលគួរកត់សម្គាល់នោះគឺ នៅលើផ្នូងសក់របស់បដិមានេះ ពុំមានចម្លាក់ចំណិតព្រះចន្ទដូចរូបតំណាងព្រះសិវដែលគេតែងឃើញឡើយ។ រូបភាពបែបនេះ គេមិនធ្លាប់ឃើញនៅក្នុងសិល្បៈខ្មែរនាសម័យជាមួយគ្នាឡើយ ប៉ុន្តែ បដិមានេះបែរជាស្រដៀងទៅនឹងបដិមាមួយអង្គរកឃើញនៅប្រាសាទ A4 ក្នុងតំបន់ប្រាសាទ My Son នៃសិល្បៈចាម្ប៉ានាស.វ.ទី៨ទៅវិញ (សព្វថ្ងៃជាខេត្តក្វាងណាម ប្រទេសវៀតណាម)។ ចំណុចនេះ តើអាចទេដែលបដិមានេះអាចមានទំនាក់ទំនងជាមួយសិល្បៈចាម្ប៉ា? ដ្បិត បុរាណដ្ឋានកំពង់ចាមកៅមានចម្ងាយប្រមាណ ១៩០ គីឡូម៉ែត្រពីតំបន់ប្រាសាទ My Son ។*

*ក្រៅអំពីនេះ បដិមានេះស្លៀកសំពត់ខ្លីចងក្បិន ភ្ជាប់ជាមួយខ្សែក្រវ៉ាត់ស្តើងមួយដែលមានក្បាលស៊ីឡាំងនៅចំកណ្តាល ដែលមានក្បាលរាងមូល និងមានខ្សែចំណងជាក្រណាត់ធ្លាក់ចុះមកក្រៅទាំងសងខាង។ ជាទូទៅ ព្រះសិវក្នុងភាពជាឥសី ទំនងត្រូវនឹងឈុតមួយដែលគេស្គាល់ថា* ***"ភិក្សាជនមូតិ"*** *ដែលជាការបង្ហាញព្រះសិវក្នុងភាពជាឥសីកំលោះដ៏ស្រស់សង្ហាដើរសុំទាន និងមានរៀបរាប់នៅក្នុងគម្ពីរស្កន្ទបុរាណ និងសិវបុរាណ។ សាច់រឿងនេះកើតឡើងនៅក្នុងព្រៃ "ដារុកវន" ដែលជាទីកន្លែងឥសីមួយក្រុមធំកំពុងធ្វើតបធម៌។ ពួកឥសីទាំងនោះមានមោទនភាពខ្លាំងណាស់លើតេជៈបារមី និងការធ្វើបូជាយញ្ញរបស់ខ្លួន រហូតភ្លេចខ្លួនថាពួកគេខ្លាំងជាងព្រះជាម្ចាស់ទៅទៀត។ ដើម្បីកម្ចាត់ភាពមានះរបស់ពួកឥសីទាំងនោះ ព្រះសិវបាននិម្មិតកាយជា "ភិក្សាជន" (ឥសីក្មេងកំលោះសុំទានដ៏សង្ហាបំផុត) ហើយព្រះវិស្ណុបាននិម្មិតកាយជា "មោហិនី" (ស្ត្រីដែលមានសម្រស់ស្អាតលើសគេ)។ នៅពេលយាងដល់ទីកន្លែងធ្វើតបរបស់ពួកឥសី ភាពស្រស់សង្ហារបស់ព្រះសិវបានធ្វើឱ្យភរិយារបស់ឥសីទាំងនោះឈ្លក់វង្វេង បោះបង់ចោលផ្ទះសម្បែង ហើយដើរតាមទ្រង់ទាំងអាការៈរវើរវាយ។ រីឯពួកឥសីក៏ឈ្លក់វង្វេងនឹងសម្រស់នាងមោហិនីដូចគ្នា រហូតធ្វើឱ្យពិធីបូជាយញ្ញរបស់ពួកគេត្រូវអាក់ខាន។ ពួកឥសីខឹងសម្បារយ៉ាងខ្លាំង ក៏ប្រើមន្តអាគមបង្កើតជាសត្វខ្លា ពស់ និងបិសាច ដើម្បីមកវាយប្រហារព្រះភិក្សាជន។ ប៉ុន្តែ ព្រះអង្គបានយកស្បែកខ្លាមកធ្វើជាសំពត់ យកពស់មកធ្វើជាគ្រឿងអលង្ការ និងជាន់ឈ្លីបិសាចនោះនៅក្រោមបាតជើង រហូតធ្វើឱ្យពួកឥសីដឹងខ្លួន ហើយសុំខមាទោសព្រះអង្គ។*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*

ដូច្នោះហើយ រូបបដិមាដែលគេស្គាល់ថា "ព្រះសិវក្នុងភាពជាឥសី" ដូចបានរៀបរាប់ខាងលើនេះ ទំនងជារូបតំណាងឱ្យព្រះសិវក្នុងទម្រង់ជាភិក្សាដនមូត៌ិក៏អាចទៅរួចដែរ។ ដ្បិត រឿងនេះជាប់ពាក់ព័ន្ធខ្លាំងទៅនឹងនិកាយបាសុបត ដែលគេដឹងច្បាស់ថាមានប្រណិប័តន៍នៅក្នុងសង្គមខ្មែរនាស.វ.ទី៧ ដូចមានរៀបរាប់នៅក្នុងសិលាចារឹកនៅសំបូរព្រៃគុក និងសិលាចារឹកប្រាសាទភ្នំព្រះវិហារ ខេត្តកំពង់ឆ្នាំង។ អ្នកបួសនៅនិកាយនេះ ជាអ្នកចូលចិត្តលាបផេះពេញខ្លួនប្រាណ និងឧស្សាហ៍ទៅកាន់ទីស្មសានដើម្បីបូជាដល់ព្រះសិវភៃរវ។

ជារួមមក បដិមាព្រះសិវក្នុងភាពជាឥសីនេះ ប្រហែលជារូបតំណាងព្រះសិវក្នុងទម្រង់មួយដែលហៅថា "ភិក្សាដនមូត៌ិ" និងអាចជាប់ពាក់ព័ន្ធជាមួយនិកាយបាសុបតនៃលទ្ធិសៃវនាស.វ.ទី៧។ បដិមានេះមានលក្ខណៈកម្រខ្លាំងណាស់នៅក្នុងសិល្បៈខ្មែរ ដែលសឹងតែគេមិនធ្លាប់បានឃើញបដិមាព្រះសិវក្នុងទម្រង់ជាមនុស្សនៅស.វ.ទី៧ឡើយ ពោល គឺមានតែចម្លាក់នានានៅលើផ្តែរទ្វារ ឬនៅតាមជញ្ជាំងប្រាសាទតែប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ បដិមានេះគេអាចសម្លឹងទៅវែងឆ្ងាយជាមួយសិល្បៈនៃអាណាចក្រចាម្ប៉ា ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីតាំងរកឃើញ។

## បញ្ជីឯកសារពិគ្រោះ


Donaldson, T.E. 1986, 'Bhiksatanamurti Image from Orissa', *Artibus Asiae*, Vol 47.

Dupont, P. (1936) 'L'art du Kulen et les débuts de la statuaire angkorienne', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 36(2), pp. 415–426.

Dupont, P. (1941) 'La statuaire préangkorienne', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 41(2), pp. 233–254.

Groslier, G. (1924) *Angkor*. Paris: Henri Laurens.

Guy, J. 2014, Lost kingdoms, Hindu-Buddhist sculpture of early Southeast Asia, The Metropolitan Museum of Art, New York. 2018, 'Shiva's land: understanding the religious landscape of early Southeast Asia', Cultural and civilizational links between India and Southeast Asia, pp. 253 – 274, edited by Shyam Saran.

Parmentier, H. (1913) 'Complément à l'Inventaire descriptif des monuments cams de l'Annam', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 13(1), pp. 1–64.

Parmentier, H. (1927) *L'Art khmer primitif*. 2 vols. Paris: G. van Oest (Publications de l'École française d'Extrême-Orient).


អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១-២៖ បដិមាព្រះសិវក្នុងភាពជាឥសី រកឃើញនៅកំពង់ចាមកៅ

KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ រ៉ាលី





រូបលេខ៣-៤៖ បដិមាព្រះសិវក្នុងភាពជាឥសី រកឃើញនៅកំពង់ចាមកៅ





រូបលេខ៥-៦៖ លម្អិតថូទឹក និងសំពត់បដិមាព្រះសិវក្នុងភាពជាឥសី រកឃើញនៅកំពង់ចាមកៅ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី